**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១១ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការប្រែក្លាយវិទ្យាស្ថានជាតិគ្រប់គ្រង ទៅជាសាកលវិទ្យាល័យជាតិគ្រប់គ្រង

*******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញសេចក្តីសំរេចលេខ ២៤ សសរ ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ១៩៩៨ របស់រាជរដ្ឋាភិបាល ស្តីពីការប្តូរឈ្មោះមហាវិទ្យាល័យពាណិជ្ជសាស្ត្រ ទៅជាសាកលវិទ្យាល័យជាតិគ្រប់គ្រង និងការបើកថ្នាក់បរិញ្ញាបត្រ សិក្សាតាមរូបភាពបង់ថ្លៃ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សំរេច

**មាត្រា ១ :** ប្រែក្លាយ វិទ្យាស្ថានជាតិគ្រប់គ្រង ទៅជា សាកលវិទ្យាល័យជាតិគ្រប់គ្រង " NATIONAL UNIVERSITY OF MANAGEMENT " ហៅកាត់ជាភាសាខ្មែរ " ស.ជ.គ " និងហៅកាត់ជាភាសាអង់គ្លេស " NUM " ។ សាកលវិទ្យាល័យនេះ ស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ២ :** សាកលវិទ្យាល័យជាតិគ្រប់គ្រង មានតួនាទីជា មជ្ឈមណ្ឌលបណ្តុះបណ្តាល ធនធានមនុស្ស ស្រាវជ្រាវ វប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកទេស ថែរក្សានិងលើកស្ទួយនូវអត្តសញ្ញាណជាតិ ។

**មាត្រា ៣ :** សាកលវិទ្យាល័យជាតិគ្រប់គ្រង ធ្វើការបណ្តុះបណ្តាល :

- ថ្នាក់បរិញ្ញាបត្រ សិក្សារយៈពេលយ៉ាងតិច ៤ ឆ្នាំ
- ថ្នាក់មាស្ទ័រ សិក្សារយៈពេលយ៉ាងតិច ២ ឆ្នាំ
- ថ្នាក់បណ្ឌិត សិក្សារយៈពេលយ៉ាងតិច ៣ ឆ្នាំ

**មាត្រា ៤ :** សាកលវិទ្យាល័យជាតិគ្រប់គ្រង មាន ៦ មហាវិទ្យាល័យ :

១. មហាវិទ្យាល័យគ្រប់គ្រង
២. មហាវិទ្យាល័យហិរញ្ញវត្ថុនិងគណនេយ្យ
៣. មហាវិទ្យាល័យទេសចរណ៍ និងបដិសណ្ឋារកិច្ច
៤. មហាវិទ្យាល័យសេដ្ឋកិច្ច
៥. មហាវិទ្យាល័យនីតិសាស្ត្រ
៦. មហាវិទ្យាល័យព័ត៌មានវិទ្យា

និង ថ្នាក់ក្រោយបរិញ្ញាបត្រ ។

សាកលវិទ្យាល័យនេះ មានសាខាមួយ ស្ថិតនៅទីរួមខេត្តបាត់ដំបង ។ ទៅអនាគត សាកលវិទ្យាល័យជាតិគ្រប់គ្រង អាចបើកសាខា មហាវិទ្យាល័យ ឯកទេស កំរិត ឬប្រភេទបណ្តុះបណ្តាលដទៃទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៥ :** តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់សាកលវិទ្យាល័យជាតិគ្រប់គ្រង ត្រូវកំណត់ដោយប្រកាសរបស់ក្រសួង អប់រំ យុវជន និងកីឡា ។

**មាត្រា ៦ :** សាកលវិទ្យាល័យជាតិគ្រប់គ្រង ដឹកនាំដោយ សាកលវិទ្យាធិការមួយរូប ដែលមានការតែងតាំងដោយព្រះរាជក្រឹត្យ និងមានសាកលវិទ្យាធិការរង ជាជំនួយការ តាមតំរូវការចាំបាច់ ដែលតែងតាំងដោយអនុក្រឹត្យ ។

**មាត្រា ៧ :** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៨ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ២០០៤

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- សាលាក្រុងភ្នំពេញ
  "ដើម្បីជូនព័ត៌មាន"
- ដូចមាត្រា ៨
  "ដើម្បីអនុវត្ត"
- កាលប្បវត្តិ -ឯកសារ